# អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA))

National Inforamtion Communications Technology Development Authority (NiDA)

# របៀបវាយអត្ថបទតាមតាមនិយាម NiDA យូនីកូដខ្មែរ ជំនាន់ទី២

How to type text base on NiDA Standard Khmer Unicode V2

ក្រុមការងារអភិវឌ្ឍន៍ធនធានមនុស្ស និង ប្រភពកូដចំហ

© អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA)) ក្រុមការងារអភិវឌ្ឍន៍ធនធានមនុស្ស និង ប្រភពកូដចំហ (**សួខ ណាយ**)

# មាតិកា


ប្លង់ក្តារចុចខ្មែរយូនីកូដ....................................................................................................២
១. ស្វែងយល់អំពីការប្រើប្រាស់ ក្តារចុច ៖.....................................................................................២
ប្លង់ក្តារចុចខ្មែរយូនីកូដ..................................................................................................២
របៀបប្តូរក្តារចុច មកជាក្តារចុចខ្មែរ ៖.....................................................................................៣
២. ស្វែងយល់អំពី គ្រាប់ចុច (Key) ៖.........................................................................................៣
៣. ស្វែងយល់ពីការប្រើប្រាស់គ្រាប់ចុចមួយចំនួន ៖.........................................................................៣
រៀនវាយតាមខាងក្រោម ៖.......................................................................................................៣
៤. ចូរវាយ ព្យញ្ជនៈដូចខាងក្រោម ៖...........................................................................................៣
៥. ចូរវាយ ស្រៈនិស្ស័យដូចខាងក្រោម ៖.......................................................................................៤
៦. ចូរវាយ ស្រៈពេញតួ ដូចខាងក្រោម ៖.......................................................................................៤
៧. ចូរវាយ សញ្ញាលើ (វណ្ណយុត្តិដែលនៅលើ )...............................................................................៤
៨. ចូរវាយ សញ្ញាវណ្ណយុត្តិខ្មែរ ដូចខាងក្រោម ៖.............................................................................៤
៩. ចូរវាយ ព្យញ្ជនៈ ផ្សំជាមួយ ស្រៈ ដូចខាងក្រោម ៖.......................................................................៤
១០.ចូរវាយ លេខ ដូចខាងក្រោម ៖..............................................................................................៤
១១. របៀបវាយ ជើងព្យញ្ជនៈ ៖....................................................................................................៤
១២. ត្រីសព្ទ ( ៊) និង មូលសិកទន្ត ( ៉) ៖.........................................................................................៥
១៣. ការប្រើប្រាស់គ្រាប់ចុច ចន្លោះមិនឃើញ.....................................................................................៥
១៤. សញ្ញាវណ្ណយុត្តិ (សញ្ញាលើ) ៖...............................................................................................៦

# របៀបវាយយូនីកូដខ្មែរ

១. ស្វែងយល់អំពីការប្រើប្រាស់ **ក្តារចុច** ៖

## ប្លង់ក្តារចុចខ្មែរយូនីកូដ

*ស្វែងយល់ឈ្មោះគ្រាប់ចុចជាភាសាខ្មែរ*




អ្នកអាចដឹងថា ក្តារចុចរបស់អ្នកកំពុងស្ថិតក្នុងភាសាអ្វីបាន ដោយមើលទៅជ្រុងខាងក្រោមផ្នែកខាងស្តាំនៃអេក្រង់ម៉ូនីទ័រកុំព្យូទ័ររបស់អ្នក ដូចមានបង្ហាញក្នុងរូបខាងក្រោម ៖




ប្រសិនបើឃើញអក្សរ **EN** នេះជាទម្រង់ខ្លីរបស់ English មានន័យថា កុំព្យូទ័ររបស់អ្នកកំពុងតែប្រើប្រាស់ក្តារចុចជាភាសាអង់គ្លេស ដូច្នេះគ្រាប់ចុចទាំងអស់ដែលអ្នកបានវាយ នឹងលេចឡើងតួអក្សរជាភាសាអង់គ្លេស។

ប្រសិនបើឃើញអក្សរ **CA** មានន័យថា កុំព្យូទ័ររបស់អ្នកកំពុងប្រើប្រាស់ក្តារចុចខ្មែរ ដូច្នេះគ្រាប់ចុចទាំងអស់ដែលអ្នកបានវាយនឹងលេចឡើងជាតួអក្សរខ្មែរ ។

*ចំណាំ ៖ ដើម្បីវាយអក្សរខ្មែរ អ្នកត្រូវប្តូរក្តារចុចមកជាក្តារចុចខ្មែរជាមុនសិន ។*

© អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA)) ក្រុមការងារអភិវឌ្ឍន៍ធនធានមនុស្ស និង ប្រកពកូដចំហ (**សួន ណាយ**)

- ***របៀបប្តូរក្តារចុច មកជាក្តារចុចខ្មែរ ៖***

  → បញ្ជាព្រួញកណ្តុរ ចុចលើអក្សរ **EN** រួចហើយជ្រើសយក **CA** ។




កំពុងប្រើក្តារចុចអង់គ្លេស ត្រូវបានប្តូរមកជាក្តារចុចខ្មែរ

២. ស្វែងយល់អំពី **គ្រាប់ចុច** (Key) ៖

ចូរមើលលើប្លង់ក្តារចុចយូនីកូដខ្មែរ ។ ***ឧទាហរណ៍*** ៖ គ្រាប់ចុច រ




- ដើម្បីវាយអក្សរ ស ចុចគ្រាប់ចុច *ស* ធម្មតា
- ដើម្បីវាយអក្សរ ៃ ចុចគ្រាប់ចុច ***ប្តូរ* (Shift) +** *ស*
- ដើម្បីវាយអក្សរ គ ចុចគ្រាប់ចុច ***ឆ្លាស់* (Alt Gr) +** *ស*

៣. ស្វែងយល់ពីការប្រើប្រាស់គ្រាប់ចុចមួយចំនួនដូចជា ៖

- គ្រាប់ចុច *លុប ←(BackSpace)* ៖ សម្រាប់លុបអក្សរថយក្រោយ ឬ មកឆ្វេងម្តងមួយតួអក្សរ ។
- គ្រាប់ចុច *លុប* ***(Delete)*** ៖ សម្រាប់លុបអក្សរទៅមុខ ឬ ទៅស្តាំម្តងមួយតួអក្សរ ។
- គ្រាប់ចុច ***ប្តូរ* (Shift) +** ***ចន្លោះមិនឃើញ*** *(Space bar)* ៖ សម្រាប់វាយដកឃ្លាម្តងមួយតួអក្សរ ។
- គ្រាប់ចុច *ព្រួញ*  ៖ សម្រាប់នាំទស្សន៍ទ្រនិច(Cursor) ទៅឆ្វេង (←) ឬទៅស្តាំ (→) ម្តងមួយតួអក្សរ និង ឡើងលើ (↑) ឬ ចុះក្រោម (↓) ម្តងមួយបន្ទាត់ ឬមួយជួរ ។
- គ្រាប់ចុច *ដើម (Home)* ៖ សម្រាប់នាំទស្សន៍ទ្រនិចមកដើមបំផុតនៃបន្ទាត់ ។
- គ្រាប់ចុច *ចុង (End)* ៖ សម្រាប់នាំទស្សន៍ទ្រនិចទៅចុងបំផុតនៃបន្ទាត់ ។

***រៀនវាយតាមខាងក្រោម ៖***

*ចំណាំ ៖ សូមមើលប្លង់ក្តារចុច ដើម្បីវាយអក្សរដូចខាងក្រោម ៖*

៤. ចូរវាយ **ព្យញ្ជនៈ**ដូចខាងក្រោម ៖

***ចំណាំ*** ៖ ចុចគ្រាប់ចុច *ប្តូរ (Shift)+**ចន្លោះមិនឃើញ** (Spacebar)* ដើម្បីវាយដកឃ្លាចន្លោះព្យញ្ជនៈនីមួយៗ

ក ខ គ ឃ ង

ច ឆ ជ ឈ ញ

ដ ឋ ឌ ឍ ណ

ត ថ ទ ធ ន

ប ផ ព ភ ម

យ រ ល វ ស ហ ឡ អ

៥. ចូរវាយ **ស្រៈនិស្ស័យ**ដូចខាងក្រោម ៖

*ចំណាំ* ៖ ចូរវាយដកឃ្លាចន្លោះស្រៈនីមួយៗ

◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌េ ◌ែ ◌ៃ ◌ោ ◌ៅ ◌ុំ ◌ំ ◌ាំ ◌ះ ◌ុះ ◌េះ ◌ោះ

៦. ចូរវាយ **ស្រៈពេញតួ** ដូចខាងក្រោម ៖

ឥ ឦ ឧ ឩ ឪ ឨ ឫ ឬ ឭ ឮ ឯ ឱ ឲ ឳ

៧. ចូរវាយ **សញ្ញាលើ** (វណ្ណយុត្តិដែលនៅលើ )

◌៉ ◌៊ ◌៏ ◌៌ ◌៍ ◌់ ◌៑

◌័ ◌៎

៨. ចូរវាយ **សញ្ញាវណ្ណយុត្តខ្មែរ** ដូចខាងក្រោម ៖

។ ៕ ៖ ៗ ◌ៈ ៙ ៚

៩. ចូរវាយ **ព្យញ្ជនៈ** ផ្សំជាមួយ **ស្រៈ** ដូចខាងក្រោម ៖

*ចំណាំ* ៖ ស្រៈត្រូវវាយបន្ទាប់ពីព្យញ្ជនៈ ។

កា កិ កី កឹ កឺ

ខុ ខូ គួ គើ គឿ គៀ គេ ចៃ ចៃ ចោ ឆៅ ជុំ ងុំ

សុំ ចាំ ជុះ ឆេះ លើ លោះ ឃុំ កេះ ប៉ៅ

ជិះ កែះ ទឺះ (ស្រៈ ◌ិ◌ះ ◌ែ◌ះ និង ◌ឺ◌ះ មិនត្រូវបានទទួលស្គាល់ថាជាស្រៈខ្មែរ ដូច្នេះ វាមិនត្រូវបានបញ្ចូលក្នុងក្តារចុចខ្មែរទេ បើចង់វាយត្រូវផ្សំស្រៈជាមួយនឹងសញ្ញារះមុខ) ។

១០. ចូរវាយ **លេខ** ដូចខាងក្រោម ៖

០ ១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩

២០០៥ ១៩៩៨ ២០០១

៣,៣២៣.០០៛

(៨៥៥) ១២ ៩៨៤៣២៥

១១. របៀបវាយ ជើងព្យញ្ជនៈ ៖

*ចំណាំ* ៖ គ្រាប់ចុច J = ◌្ ជាសញ្ញាសម្រាប់ដាក់ជើង ។ រៀនវាយជើងព្យញ្ជនៈដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ◌្ + ក ◌្ក | ◌្ + ត ◌្ត | ◌្ + ដ ◌្ដ | ◌្ + រ ◌្រ |
| ◌្ + ទ ◌្ទ | ◌្ + ធ ◌្ធ | ◌្ + អ ◌្អ | ◌្ + ញ ◌្ញ |

រៀនវាយពាក្យដូចខាងក្រោម៖

*ចំណាំ*៖ ជើងព្យញ្ជនៈត្រូវតែវាយ បន្ទាប់ពីព្យញ្ជនៈ និង វាយមុនស្រៈ ។ គឺត្រូវវាយតាមលំដាប់ប្រកប ។

ត្រូវវាយតាមក្បួនទូទៅមួយ ៖ ព្យញ្ជនៈ + **ជើងព្យញ្ជនៈ** + ស្រៈ

© អាជ្ញាធរជាតិ ទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា (NiDA) ) ក្រុមការងារអភិវឌ្ឍន៍ធនធានមនុស្ស និង ប្រកពកូដចំហ (**សួន ណាយ**)

ក + ្ + ល + ើ ក្លើ

ស + ្ + រ+ី ស្រី

ខ + ្ + ញ +ុ+ំ ខ្ញុំ

ស + ញ + ្ + ញ + ា សញ្ញា

រៀនវាយពាក្យដូចខាងក្រោម ៖

*ចំណាំ*៖ ្រ ត្រូវតែវាយក្រោយជើងណាណាទាំងអស់ ក្នុងករណីមានជើងព្យញ្ជនៈពីរ ឬច្រើនដែលមានមួយជា ្រ ។

*ឧទាហរណ៍ ៖*

ស + ្ + ត + ្ + រ +ី ស្ត្រី

ស + ង + ្ + គ + ្ + រ +ុ+ ប សង្គ្រុប

*វាយពាក្យដូចខាងក្រោម*

អង្គ្រង ចង្ក្រាន សង្គ្រោះ សង្គ្រាម ឥន្ទ្រី តន្ត្រី កញ្ជ្រោង កញ្ច្រែង មន្ត្រី កន្ត្រៃ

១២. **ត្រីសព្ទ** ( ៊) និង **មូសិកទន្ត** ( ៉) ៖

*ចំណាំ*៖ កុំវាយ ុ ជំនួសឲ្យ ៊ ឬ ៉ ។ ៊ ឬ ៉ ត្រូវវាយបន្ទាប់ពី ជើងព្យញ្ជនៈ និងមុនស្រៈ ។

ស +៊ +ី ស៊ី　　　　កុំវាយ ស +ី +ុ ឬ ស+ុ+ី

ប +៉+ី ប៉ី　　　　កុំវាយ ប +ី+ុ

*វាយពាក្យដូចខាងក្រោម*

កុងស៊ី តឹងរ៉ឹង នាម៉ឺន ប៊ឺតប៉ោង ប៊ីដុង ម៉ាស៊ីន រប៉ិលរប៉ូច កំប៉ិកកំប៉ុក ប៉ប៉ិលប៉ប៉ូច ម៉្លឹង បន្ស៊ី រង្ស៊ី ស្នោកគ្រោក ឫស្ស៊ី ស្រ៊ុប

១៣. ការប្រើប្រាស់គ្រាប់ចុច **ចន្លោះមិនឃើញ** (គ្រាប់ចុចដែលវែងជាងគេលើក្ដារចុច) ៖

ប្រសិនបើអ្នកចុចគ្រាប់ចុច *ចន្លោះមិនឃើញ* នោះតួអក្សរដែលបានបញ្ចូលទៅក្នុងអត្ថបទ គឺជាចន្លោះមួយដែលមើលមិនឃើញ ។ ប្រសិនបើ អ្នកចង់វាយ **ដកឃ្លា** អ្នកត្រូវចុច គ្រាប់ចុច **ប្ដូរ** (Shift) ឲ្យជាប់ រួចហើយចុចគ្រាប់ចុច *ចន្លោះមិនឃើញ* (Space bar) ។

នៅក្នុងភាសាលោកខាងលិច ដែលប្រើចន្លោះ ដើម្បីបំបែកពាក្យនោះ ប្រាកដជាមិនមានបញ្ហាឡើយ ប៉ុន្តែ ក្នុងភាសាខ្មែរ ចន្លោះ ឬ ដកឃ្លាមិនត្រូវបានប្រើសម្រាប់ចែកពាក្យឡើយ ដូច្នេះ យើងត្រូវប្រើ គ្រាប់ចុច *ចន្លោះមិនឃើញ* ដើម្បី ខណ្ឌចែកពាក្យខ្មែរ ។ ហើយត្រូវវាយចន្លោះមិនឃើញបន្ទាប់ពីពាក្យនីមួយៗ ។

ឧទាហរណ៍ ៖ ចន្លោះមិនឃើញ

*ខ្ញុំទៅសាលារៀន*

+ **ចន្លោះភ្ជាប់** (វាយដោយប្រើ គ្រាប់ចុច ***ផ្លាស់*** (Alt GR) + ***ចន្លោះមិនឃើញ*** (spacebar))

- ប្រើសម្រាប់ដកឃ្លា ដោយភ្ជាប់តួអក្សរ ឬពាក្យ។
- គួរវាយពីមុខសញ្ញា ។ ៖ !

**ឧទា ៖**




វាយពាក្យដូចខាងក្រោម ៖

**ចំណាំ ៖** *មិនត្រូវវាយជើង ត ជំនួសឲ្យជើង ដ ឬ ជើង ដ ជំនួសឲ្យជើង ត ទេ ។ ត្រូវវាយតាមពាក្យ ដែលបានប្រកបយ៉ាងត្រឹមត្រូវ ពីព្រោះវាអាចមានផលវិបាកនៅពេលក្រោយ ប្រសិនបើអ្នកវាយមិនត្រឹមត្រូវតាមក្បួន ។*

ទីផ្សារ ប្រាសាទ សម្រេច ថ្លុក ថ្លើម ប្រាង្គ សេចក្តី ផ្តិល ផ្តល់ ព្រមព្រៀង រដ្ឋាភិបាល ប៉ុន្មាន បច្ចេកទេស ចុំថ្លើង បុព្វហេតុ សុទិដ្ឋិនិយម អភិវឌ្ឍន៍ ប្រោះព្រំ ក្បិណក្ប៉យ អនុញ្ញាត

១៤. សញ្ញាវណ្ណយុត្តិ (**សញ្ញាលើ**) ៖

**សញ្ញាលើ មានដូចជា ៖** ៍ ៉ ៌ ៈ ៎ ៏ ័

**ចំណាំ ៖** *សញ្ញាលើ ត្រូវវាយបន្ទាប់ពីព្យញ្ជនៈ និង មុនស្រៈ ។*

**ចំណាំពិសេស ៖** ិ + ៍ = ិ៍

ត្រូវវាយតាមក្បួនទូទៅមួយ ៖ ព្យញ្ជនៈ + **សញ្ញាលើ** + ស្រៈ

វាយពាក្យដូ ចខាងក្រោម៖

ទុគិត ទុយ៉ិស បរិប្ញូរណ៍ លោមព័ណ៌ ព័ត៌មាន យុត្តិធម៌ សម្បូណ៌ ពោធិ៍ ប្រាក់ ស៊ីម៉ងត៍ ប៉ុងតោ សពេជ្ញ អជិន កាប៉ាស បូណ៌មី សាពាង្គកាយ

សូមវាយអត្ថបទដូចខាងក្រោម ៖

- ឆ្នាខ្ញុំចូលចិត្តស៊ីត្រី ។
- ខ្ញុំជាស្ត្រី ចូលចិត្តញ៉ាំបាយ ។
-កម្ពុជា ជាប្រទេសសម្បូរទៅដោយសម្បត្តិវប្បធម៌ អរិយធម៌ និង ធនធានធម្មជាតិ ព្រមទាំងមាន ប្រាង្គ ប្រាសាទ ជាច្រើនទៀតផង ។